សួស្តី នៅក្នុងរូបភាពនេះគឺនិយាយអំពីការគ្រុនផ្តាសាយ។
ដែលនៅក្នុងរូបភាពទី ១ យើងឃើញមានបុរសម្នាក់ ដែលគាត់ពាក់អាវពណ៌ទឹកក្រូចដៃខ្លី
ជាមួយនឹងខោសជើងវែង។ គាត់ទើបតែចេញមកពីធ្វើការ
ដូច្នេះយើងឃើញគាត់កំពុងតែដើរនៅតាមផ្លូវ ដើម្បីទៅ ដើម្បីទៅរកចំណតឡានក្រុង
និងជិះឡានក្រុងត្រលប់ទៅផ្ទះវិញ ប៉ុន្តែនៅពេលដែលគាត់ដើរនៅតាមផ្លូវ
ភ្លៀងក៏បានធ្លាក់ចុះមកយ៉ាងខ្លាំង ដោយសារតែគាត់មិនបានយកឆត្រ និងអាវភ្លៀងមកជាមួយ
ដូច្នេះយើងឃើញខ្លួនរបស់គាត់ទទឹក និងនៅក្នុងដៃរបស់គាត់មានកាន់សៀវភៅមួយ។
គាត់ក៏បានបើកសៀវភៅនោះយកមកបាំងនៅលើក្បាលរបស់គាត់កុំឲ្យ
កុំឲ្យក្បាលរបស់គាត់ទទឹកភ្លៀង និងពេលខ្លះនៅពេលដែលភ្លៀងខ្លាំង
យើងឃើញតំណក់ទឹកភ្លៀងធ្លាក់មកធំៗ ដូច្នេះធ្វើឲ្យយើងពិបាកមើលផ្លូវ
ដោយសារតែនៅពេលដែលតំណក់ទឹកភ្លៀងធ្លាក់ចុះមកប៉ះនឹងមុខយើង មានអារម្មណ៍ថាឈឺមុខ
មានអារម្មណ៍ថាឈឺមុខ ដូចជាស្រមោចខាំ ដោយសារតែតំណក់ទឹកភ្លៀងនោះធំៗ ដូច្នេះ
ដូច្នេះគាត់ក៏បានយក គាត់ក៏បានយកសៀវភៅយកមកបាំងនៅលើក្បាលគាត់
ដើម្បីអាចរត់យ៉ាងលឿនទៅរកចំណតឡានក្រុង និងដើម្បីចៀសវាងកុំឲ្យទទឹកក្បាលផងដែរ។
ដោយសារតែនៅពេលដែលមានភ្លៀង ដោយសារតែនៅពេលដែលមានភ្លៀង
និងយើងដើរកាត់ភ្លៀងដោយមិនបាន ដោយមិនបានប្រើឆត្រ ឬក៏មិនបានប្រើ មិនបានប្រើអាវភ្លៀង
វាងាយស្រួលធ្វើឲ្យយើងឈឺ និងផ្តាសាយ ដោយសារតែប្រព័ន្ធនៅក្នុងខ្លួនរបស់យើង
នៅពេលប៉ះជាមួយនឹងទឹកភ្លៀង ធ្វើឲ្យប្រព័ន្ធនៅក្នុងខ្លួនរបស់យើងខ្សោយជាងមុន ខ្សោយជាងមុន
ដូច្នេះងាយស្រួលនឹងផ្តាសាយណាស់ អញ្ចឹងជាពិសេសខែដែលមនុស្សគាត់ផ្តាសាយ
និងឈឺច្រើនគឺនៅខែ នៅខែភ្លៀង និងខែត្រជាក់។ អញ្ចឹងមនុស្សងាយស្រួលផ្តាសាយ និងក្តៅខ្លួន
និងឈឺជំងឺផ្សេងៗ ជាពិសេសគឺផ្តាសាយតែម្តង។ អញ្ចឹងបុរសនៅក្នុងរូបភាពទី ១ នេះ
ដោយសារតែគាត់មិនបានយកអាវភ្លៀងនិងឆត្រមកជាមួយ គាត់ក៏បានយកសៀវភៅ យក
គាត់ក៏បានបើកសៀវភៅនៅក្នុងដៃទាំងពីររបស់គាត់យកមកបាំងក្បាលរបស់គាត់ដើម្បីទទឹក
និងដើម្បី ដើម្បីអាចមើលផ្លូវ និងដើម្បីអាចមើលផ្លូវឃើញផង
ដោយសារតែតំណក់ទឹកភ្លៀងនៅពេលធ្លាក់ប៉ះនឹងមុខគាត់ ធ្វើឲ្យមានអារម្មណ៍ថាឈឺមុខ
ដូចជាស្រមោចខាំ និងនៅពេលដែលមានភ្លៀងខ្លាំងធ្វើឲ្យយើងពិបាកមើលផ្លូវផងដែរ។
អញ្ចឹងគាត់ក៏បានយកសៀវភៅនោះយកមកបាំងដើម្បីរត់ ដើម្បីរត់ទៅកាន់ចំណតរថយន្ត
ដើម្បីរត់ទៅកាន់ចំណតរថយន្ត។

បន្ទាប់មកទៀតរូបភាពទី ២ រូបភាពទី ២ គាត់ក៏បានរត់ គាត់ក៏បានរត់មកដល់ចំណតរថយន្ត
និងគាត់ក៏បានឡើងទៅលើឡានក្រុង ដើម្បីជិះត្រលប់ទៅផ្ទះវិញ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយយើងឃើញខ្លួនរបស់គាត់គឺទទឹក អញ្ចឹងខោអាវរបស់គាត់គឺទទឹកជោក
ដោយសារតែគាត់បានរត់កាត់ភ្លៀងដោយមិនបានប្រើឆត្រ និងមិនបានប្រើអាវភ្លៀង
ដូច្នេះយើងឃើញខ្លួនរបស់គាត់ទទឹកជោក។ គាត់ក៏បានឡើងទៅលើឡានក្រុង
ប៉ុន្តែនៅលើឡានក្រុងអត់មាននៅសល់កៅអី ដូច្នេះគាត់ក៏បានឈរ
គាត់ក៏បានឈរនៅក្នុងឡានក្រុងដោយកាន់ដែក ដែលមាននៅក្នុងឡានក្រុងនោះ
ដើម្បីកុំឲ្យដួលនៅពេលដែលឡានក្រុងឈប់ ឬក៏នៅពេលដែលឡានក្រុងចាប់ហ្វ្រាំង
អញ្ចឹងយើងឃើញមានមនុស្សជាច្រើនគាត់អង្គុយនៅក្នុងឡានក្រុងនោះ យើងឃើញបុរសម្នាក់នោះ
គាត់បានឈរនៅ នៅទល់មុខបុរសម្នាក់ទៀត [...] នៅទល់មុខបុរសម្នាក់ទៀត
ដែលបុរសម្នាក់ទៀតនោះ យើងឃើញគាត់ពាក់អាវយឺតពណ៌ស យើងឃើញគាត់ពាក់អាវយឺត
[ពណ៌]យឺតដៃខ្លីពណ៌សជាមួយនឹងខោ ជាមួយនឹងខោជើង ជាមួយនឹងខោពណ៌សជើងវែង
បុរសម្នាក់នោះដៃម្ខាងកាន់ដែកនោះ ដៃម្ខាងទៀតទប់ ដៃម្ខាងទៀតទប់មាត់ ដោយសារតែគាត់ក្អក
និងផ្តាសាយយ៉ាងខ្លាំង ដោយសារតែគាត់ក្អក និងផ្តាសាយ និងមានហៀរសំបោរផងដែរ។
អញ្ចឹងគាត់បានយកដៃម្ខាងទៀតទប់ ប៉ុន្តែដោយសារតែគាត់ក្អកនិងផ្តាសាយហៀរសំបោរខ្លាំង
ដូច្នេះដៃរបស់គាត់ទប់ ទប់ ដៃរបស់គាត់គឺទប់មិន ទប់អត់ឈ្នះ ដោយសារតែ
ដោយសារតែមានការហៀរសំបោរខ្លាំង ដូច្នេះយើងឃើញបុរសម្នាក់នោះបានឈរនៅ
យើងឃើញបុរសដែលគាត់បានរត់កាត់ភ្លៀងនោះបាន បានឈរនៅខាងមុខគាត់
និងបានឈរនៅខាងមុខគាត់ អញ្ចឹងក្រោយពេលដែល
ក្រោយពេលដែលគាត់ឃើញបុរសម្នាក់នោះកំពុងតែក្អកផងផ្តាសាយ និងហៀរសំបោរផង គាត់ក៏ឈរ
និងសម្លឹងទៅបុរសម្នាក់នោះ ដោយមិនបានយកដៃខ្ទប់ ដោយមិនបានយកដៃខ្ទប់ច្រមុះទេ
គាត់មិនបានដឹងថាជំងឺផ្តាសាយអាចឆ្លងបានយ៉ាងងាយស្រួល ដោយឈរនៅខាងមុខ
ដោយឈរនៅខាងមុខអ្នកដែលមានជំងឺផ្តាសាយនោះ អញ្ចឹងជំងឺផ្តាសាយអាចឆ្លងតាមរយៈ
តាមរយៈវីរុស តាមរយៈវីរុស ឬក៏បាក់តេរីដែលកើតចេញពីការក្អក និងផ្តាសាយ
និងហៀរសំបោរនោះ អញ្ចឹងនៅពេលដែលយើងនៅជិតអ្នកដែលមានជំងឺផ្តាសាយ
យើងត្រូវពាក់ម៉ាសការពារ ឬក៏នៅពេលដែលអ្នកដែលមានជំងឺផ្តាសាយនោះក្អក ឬក៏ផ្តាសាយ
មានហៀរសំបោរ យើងត្រូវចៀសវាងនៅឲ្យឆ្ងាយពីគាត់ យើងត្រូវចៀសវាងនៅឲ្យឆ្ងាយពីគាត់
ពីព្រោះនៅពេលដែលគាត់ក្អក វីរុសនោះនឹងងាយស្រួលក្នុងការមកប៉ះខ្លួនរបស់យើង
និងងាយស្រួលចម្លងមកក្នុងខ្លួនរបស់យើងផងដែរ
ជាពិសេសនៅពេលដែលខ្លួនរបស់យើងទទឹកជោក និងនៅពេលដែលយើងដើរឆ្លងកាត់ភ្លៀង
អញ្ចឹងយើងឃើញបុរសម្នាក់នោះ គាត់មិនបានយកដៃរបស់គាត់យកមកបិទច្រមុះ ឬងាកចេញ
ឬងាក ឬងាកមុខចេញ ឬក៏មិនបានពាក់ម៉ាស ដាក់ ឬក៏មិនបានពាក់ម៉ាសទេ
អញ្ចឹងគាត់មិនបានចាប់អារម្មណ៍ថាគាត់នឹងអាចឆ្លងជំងឺផ្តាសាយពីបុរសម្នាក់នោះទេ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៣ រូបភាពទី ៣ គាត់ក៏បានជិះឡានក្រុងមកដល់ផ្ទះរបស់គាត់
បន្ទាប់មកគាត់ក៏បានបើកទ្វារចូលមកក្នុងផ្ទះរបស់គាត់ ដោយយើងឃើញ
ដោយយើងឃើញខ្លួនរបស់គាត់ទទឹកជោក
និងយើងឃើញនៅខាងក្រៅមានភ្លៀងធ្លាក់កាន់តែខ្លាំងឡើងៗ និងតំណក់ទឹកភ្លៀង
យើងឃើញគ្រាប់របស់វាគឺធំៗ គឺធំៗ អញ្ចឹងភ្លៀងធ្លាក់កាន់តែខ្លាំងឡើង
គាត់ក៏បានបើកទ្វារចូលមកក្នុងផ្ទះ ដោយខ្លួន ដោយខ្លួនរបស់គាត់ទទឹក
គាត់ក៏មានអារម្មណ៍ថាដូចជាមិនសូវស្រួលខ្លួន និងមានអារម្មណ៍ថាគាត់ប្រហែលជាផ្ដាសាយ
ដោយសារតែគាត់ដើរឆ្លងកាត់ភ្លៀង និងខ្លួនទទឹក
និងដោយសារតែគាត់ឈរនៅខាងមុខអ្នកដែលកើតជំងឺផ្ដាសាយ ក្អក និងហៀរសំបោរនោះផងដែរ។
ដូច្នេះគាត់គិតថា គាត់នឹង ដូច្នេះគាត់គិតថា គាត់ប្រហែលជាមានជំងឺផ្ដាសាយ គាត់ប្រហែលជា
គាត់គិតថា គាត់ប្រហែលជាមានជំងឺផ្ដាសាយ ដោយសារតែខ្លួនរបស់គាត់ទទឹក និងត្រូវទឹកភ្លៀង[...]
គាត់ឈរនៅខាងមុខអ្នកដែលមានជំងឺផ្ដាសាយនោះ ដោយគាត់មិនបានខ្ទប់មុខ ឬក៏បិទម៉ាស
ឬក៏ងាកមុខចេញ។

បន្ទាប់មកទៀតរូបភាពទី រូបភាពទី ៤ រូបភាពទី ៤
ដោយសារតែគាត់មានអារម្មណ៍ថាមិនសូវស្រួលខ្លួន គាត់ក៏មិន
ដោយសារតែគាត់មានអារម្មណ៍ថាមិនសូវស្រួលខ្លួន គាត់ក៏បានដើរទៅចូលបន្ទប់គេងរបស់គាត់
និងគាត់ក៏បាន គាត់ក៏បានឡើងទៅលើគ្រែគេង ដែលគាត់មិនបានប្ដូរខោអាវដែលទទឹកនោះទេ។
អញ្ចឹងនៅពេលដែលយើង នៅពេលដែលយើងដើរកាត់ភ្លៀង
ជាពិសេសនៅពេលដែលខោអាវយើងទទឹក យើងត្រូវទៅងូតទឹក យើងត្រូវទៅងូតទឹក
និងប្ដូរសម្លៀកបំពាក់ទទឹកនោះចេញ ចៀសវាងកុំឲ្យឈឺ និងផ្ដាសាយទាន់
អញ្ចឹងដោយសារតែគាត់មានអារម្មណ៍ថាមិនសូវស្រួលខ្លួនខ្លាំង និងមានអារម្មណ៍ថាដូច
និងមានអារម្មណ៍ថាចង់សម្រាក មានអារម្មណ៍ថាចង់សម្រាក ដូច្នេះគាត់មិនបានញ៉ាំបាយពេលល្ងាច
គាត់មិនបានញ៉ាំបាយពេលល្ងាច និងគាត់ និងគាត់ក៏មិនបានប្ដូរសម្លៀកបំពាក់របស់គាត់ដែរ។
អញ្ចឹងគាត់ក៏បានដើរចូលទៅក្នុងបន្ទប់គេងរបស់គាត់ និងសម្រាកបន្តិច ប្រហែលជាគាត់គិតថា
គាត់ចង់សម្រាកបន្តិច ដើម្បីឲ្យមានអារម្មណ៍ស្រួលខ្លួន បន្ទាប់មកគាត់ប្ដូរខោអាវ និងញ៉ាំបាយ
ប៉ុន្តែដោយសារតែគាត់មានអារម្មណ៍ថាមិនស្រួលខ្លួនខ្លាំង គាត់ក៏បានគេងលក់
គាត់ក៏បានគេងលក់រហូតដល់មេឃភ្លឺ គាត់ក៏បានគេងលក់រហូតដល់មេឃភ្លឺ
ដោយមិនបានប្ដូរសម្លៀកបំពាក់ដែលទទឹកនោះចេញ និងគាត់បាន
ដោយសារតែមានអារម្មណ៍ថារងា គាត់ យើងឃើញគាត់គេងនៅលើ គាត់គេងនៅលើគ្រែរបស់គាត់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដែលយើងឃើញគាត់កើយខ្នើយ និងដណ្តប់ភួយ ដោយសារតែគាត់មានអារម្មណ៍ថារងា
អញ្ចឹងយើងឃើញគាត់ដណ្តប់ភួយរបស់គាត់ អញ្ចឹងគាត់គេងលក់យ៉ាង គាត់គេងលក់យ៉ាងស្រួល
ដោយមិនដឹង ដោយមិនបាន ដោយមិនបានផ្លាស់ខោអាវចេញ
ដោយមិនបានផ្លាស់ខោអាវទទឹកចេញ អញ្ចឹងគាត់គេងលក់រហូតដល់ រហូតដល់មេឃភ្លឺ។
អញ្ចឹងនៅពេលដែលមេឃភ្លឺ ព្រះអាទិត្យរះ ព្រះអាទិត្យរះក៏ ព្រះអាទិត្យរះ
និងមានពន្លឺចាំងចូលទៅតាមបង្អួចរបស់គាត់ គាត់ក៏បានក្រោក គាត់ក៏បានក្រោកឡើង
គាត់ក៏បានក្រោកឡើង។

បន្ទាប់មកទៀត បន្ទាប់មកទៀតរូបភាពទី ៥ រូបភាពទី ៥ ក្រោយពេលដែលគាត់ក្រោកឡើង គាត់
គាត់ក៏បានក្រោកចេញពីគ្រែ និងដើរចេញ និងដើរចេញមកខាងក្រៅ ចេញមកខាងក្រៅ
ដើម្បីរកអីញុាំ ប៉ុន្តែនៅពេលដែលគាត់ដើរចេញមកខាងក្រៅ គាត់មានអារម្មណ៍ថាឈឺក
គាត់មានអារម្មណ៍ថាឈឺកយ៉ាងខ្លាំង បន្ទាប់មកគាត់ក៏ផ្តាសាយ និងហៀរសំបោរផងដែរ។
អញ្ចឹងគាត់ឈឺក ផ្តាសាយ និងហៀរសំបោរផងដែរ។ អញ្ចឹងនៅពេលដែលគាត់
នៅពេលដែលគាត់ហៀរសំបោរគាត់ក៏បានយកក្រណាត់] គាត់ក៏បានយកក្រណាត់ ឬក៏កន្សែង
ឬក៏ក្រដាសជូតមាត់មកញើសសំបោរ ដោយសារតែគាត់ហៀរសំបោរខ្លាំង
និងដោយសារតែគាត់មានអារម្មណ៍ថាតឹងច្រមុះពិបាកដកដង្ហើម
អញ្ចឹងគាត់កំពុងតែមានជំងឺផ្តាសាយ អញ្ចឹងគាត់កំពុងតែមានជំងឺផ្តាសាយ។

បន្ទាប់មកទៀតរូបភាពទី រូបភាពទី ៦ គាត់មានអារម្មណ៍ថាដូចជាក្តៅខ្លួន
គាត់មានអារម្មណ៍ថាដូចជាក្តៅខ្លួន បន្ទាប់មកគាត់ក៏យកប្រដាប់វាស់កម្តៅ
មកវាស់កម្តៅខ្លួនរបស់គាត់ អញ្ចឹងយើងឃើញកម្តៅខ្លួនរបស់គាត់គឺ គឺ គឺ កម្តៅខ្លួនរបស់គាត់គឺក្តៅ
គឺក្តៅ អញ្ចឹងគាត់ គាត់ក៏មានអារម្មណ៍ថាកាន់តែមិនស្រួលខ្លួនកាន់តែខ្លាំង ដោយសារតែឈឺក
ផ្តាសាយ ហៀរសំបោរ និងក្តៅខ្លួន អញ្ចឹងគាត់កំពុងតែមានជំងឺគ្រុនផ្តាសាយ។

បន្ទាប់មកទៀតរូបភាពទី ៧ រូបភាពទី ៧ គាត់ នៅពេលដែលគាត់
នៅពេលដែលគាត់វាស់កម្តៅខ្លួនរួចរាល់ហើយ គាត់ក៏បានថយមកអង្គុយនៅលើសាឡុងរបស់គាត់
នៅលើសាឡុងរបស់គាត់ គាត់មានអាការមិនស្រួលខ្លួនកាន់តែខ្លាំង
ដោយយើងឃើញជំងឺគ្រុនផ្តាសាយជាធម្មតានៅថ្ងៃដំបូងគឺមានអាការដូចជាឈឺក
បន្ទាប់មកហៀរសំបោរ ហៀរសំបោរ និង និងហៀរសំបោរ និងផ្តាសាយ និងផ្តាសាយ
និងតឹងច្រមុះផងដែរ តឹងច្រមុះ និងពិបាកដកដង្ហើមផងដែរ។ អញ្ចឹង និងប្រសិនបើ
និងប្រសិនបើមានជំងឺផ្តាសាយធំ ពេលខ្លះមានអាការក្តៅខ្លួនខ្លាំង និងមានអារម្មណ៍ថាឈឺពេញខ្លួន

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

មានអារម្មណ៍ថាឈឺពេញខ្លួន និងអស់កម្លាំង និងអស់កម្លាំង ដោយសារតែ ដោយសារតែគាត់ឈឺក ផ្តាសាយ ដោយសារតែឈឺកខ្លាំង ផ្តាសាយ និងមានហៀរសំបោរ និងតឹងច្រមុះខ្លាំងពិបាកដកដង្ហើម និងជាពិសេសគឺក្តៅខ្លួន និងជាពិសេសក្តៅខ្លួន ដូច្នេះធ្វើឲ្យគាត់ញ៉ាំមិនបាន គេងក៏មិន ញ៉ាំមិនបាន គេងក៏ គេងក៏ពិបាកគេង គេងក៏ពិបាកគេងដោយសារតែតឹងច្រមុះ អញ្ចឹងធ្វើឲ្យក្នុងខ្លួនរបស់គាត់ហាក់បីដូចជាគ្មានកម្លាំង ដោយសារតែគាត់មានអារម្មណ៍ថាមិនស្រួលខ្លួនកាន់តែខ្លាំង ដោយសារតែគាត់មានជំងឺផ្តាសាយធំ ដោយសារតែមានជំងឺផ្តាសាយធំ ដែលគាត់ក្តៅខ្លួនខ្លាំង ដោយគាត់ក្តៅខ្លួនខ្លាំង អញ្ចឹងគាត់ក៏បានដួសទឹកមួយកែវក្តៅៗ អ៊ុន ដួសទឹកមួយកែវក្តៅអ៊ុនៗ បន្ទាប់មកគាត់ក៏បាន គាត់ក៏បានចាក់ ចាក់ថ្នាំចូលទៅក្នុង ចាក់ថ្នាំជា ជាម្សៅចូលទៅក្នុងកែវទឹកដែលមានទឹក ដែលមានទឹកកន្លះកែវនោះ អញ្ចឹងគាត់ក៏បានចាក់ថ្នាំនោះចូលទៅក្នុងទឹក ដើម្បីលាយបញ្ចូលគ្នា បន្ទាប់មកគាត់ក៏ញ៉ាំ គាត់ក៏ញ៉ាំ គាត់ក៏ញ៉ាំថ្នាំនោះ គាត់ក៏ញ៉ាំថ្នាំនោះ។

បន្ទាប់មកទៀតរូបភាពទី ៩ ដោយសារតែនៅពេលដែលគាត់ញ៉ាំថ្នាំ ញ៉ាំថ្នាំដែលចាក់ចូលទៅក្នុងកែវលាយជាមួយទឹកនោះរួចរាល់ ប្រហែលជា ប្រហែលជា ២ ៣ ម៉ោងរួចមកគាត់នៅតែមានអាការដូចជាមិនសូវស្រួលខ្លួន គាត់នៅតែមានអាការមិនសូវស្រួលខ្លួន និងមានអារម្មណ៍ថាឈឺក និងឈឺក និង និងផ្តាសាយកាន់តែខ្លាំងឡើងៗ អញ្ចឹងគាត់ក៏បានយកថ្នាំគ្រាប់ បីគ្រាប់យកមកលេប អញ្ចឹងគាត់ក៏បានយកថ្នាំគ្រាប់ចំនួនបីគ្រាប់ ដាក់នៅលើដៃរបស់គាត់ដើម្បី ដើម្បីយកមកលេប។

បន្ទាប់មកទៀតរូបភាពទី ១០ រូបភាពទី ១០ ក្រោយពេលដែលគាត់ញ៉ាំថ្នាំហើយ គាត់ក៏បានដើរចូលទៅក្នុងបន្ទប់គេងរបស់គាត់វិញ និងសម្រាក ចូលបន្ទប់គាត់វិញ និងសម្រាក អញ្ចឹងយើងឃើញ យើងឃើញក្រោយពេលដែលគាត់ញ៉ាំថ្នាំផ្តាសាយហើយ គាត់មានអារម្មណ៍ថាងងុយគេង។ ភាគច្រើនថ្នាំផ្តាសាយនៅពេលដែលយើងញ៉ាំហើយ គឺមានអារម្មណ៍ថាងងុយគេង ពីព្រោះជាទូទៅនៅពេលដែលយើងផ្តាសាយ ទាមទារឲ្យយើងគេងឲ្យបានគ្រប់គ្រាន់ ឬក៏គេងឲ្យបានច្រើន គេងឲ្យបានច្រើន ដើម្បីឲ្យឆាប់ជាផ្តាសាយនោះ អញ្ចឹងយើងឃើញគាត់ ក្រោយពេលដែលញ៉ាំថ្នាំ គាត់ក៏បានដើរចូលទៅក្នុងបន្ទប់គេងរបស់គាត់វិញ យើងឃើញគាត់ យើងឃើញគាត់គេងនៅលើគ្រែរបស់គាត់ដោយកើយខ្នើយ និងដណ្តប់ភួយដោយសារតែគាត់រងា អញ្ចឹងដោយសារតែគាត់រងា អញ្ចឹងយើងឃើញគាត់គេងនៅពេលថ្ងៃ អញ្ចឹងដំបូងគឺគាត់គេង គាត់គេងពេលយប់រហូតដល់ភ្លឺ បន្ទាប់មកគាត់មានអាការដូចជាក្តៅខ្លួន និងផ្តាសាយកាន់តែខ្លាំង អញ្ចឹងគាត់ញ៉ាំថ្នាំ បន្ទាប់ពីញ៉ាំថ្នាំគឺគាត់ចូលទៅគេងម្តងទៀតនៅពេលថ្ងៃ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងគាត់មិនបានទៅធ្វើការទេ ដោយសារតែគាត់ ដោយសារតែគាត់ឈឺ អញ្ចឹងគាត់
គាត់ចង់គេងសម្រាកនៅផ្ទះរបស់គាត់ ដើម្បីឲ្យមាន ដើម្បីឲ្យស្រួលខ្លួនឡើងវិញ ពីព្រោះការ
ពីព្រោះប្រសិនបើគាត់ទៅធ្វើការ គាត់នឹងអាចចម្លងជំងឺផ្ដាសាយនោះ ទៅ
ទៅអ្នកដែលធ្វើការជាមួយគាត់ ទៅមិត្តរួមការងារជាមួយនឹងគាត់ អញ្ចឹងយើងឃើញគាត់ញ៉ាំថ្នាំហើយ
គាត់ក៏បានគេងសម្រាកនៅក្នុងបន្ទប់គាត់ ដោយយើងឃើញគ្រែ គ្រែគេងរបស់គាត់គឺនៅជិតបង្អួច
យើងឃើញក្រឡេកមើលនៅខាងក្រៅ យើងឃើញព្រះអាទិត្យរះ ក្រោយពេលមេឃ
ក្រោយពេលភ្លៀង គឺមេឃស្រឡះ និងព្រះអាទិត្យរះមានពន្លឺចាំងចែង ព្រះអាទិត្យរះ
មានពន្លឺចាំងចែង និងយើងឃើញមាន មានភ្នំ មានផ្ទះរបស់
ផ្ទះរបស់ប្រជាជនផ្សេងៗទៀតនៅជិតនោះផងដែរ បន្ទាប់មកទៀតគាត់
យើងឃើញគាត់គេងរហូតដល់ព្រះអាទិត្យលិច អញ្ចឹងគាត់គេងរហូតដល់ពេលល្ងាច
អញ្ចឹងមានន័យថាគាត់គេងពេញមួយថ្ងៃនៅក្នុងបន្ទប់របស់គាត់។

បន្ទាប់មកទៀតរូបភាពទី ១១ រូបភាពទី ១១ ក្រោយពេលដែលគាត់ភ្ញាក់ដឹងខ្លួន
គាត់ក៏បានក្រោកឡើង គាត់ក៏បានក្រោកឡើង គាត់ក៏ចាប់ផ្ដើមក្អក គាត់ក៏ចាប់ផ្ដើមក្អក
អញ្ចឹងជាទូទៅអាការនៃជំងឺគ្រុនផ្ដាសាយដំបូងគឺហៀរសំបោរ តឹងច្រមុះ ក្ដៅខ្លួន ហៀរសំបោរ
តឹងច្រមុះ ក្ដៅខ្លួន និងឈឺក អញ្ចឹងបន្ទាប់ពីថ្ងៃនោះគាត់ បន្ទាប់ពីថ្ងៃនោះនិង និង និងក្អក
បន្ទាប់ពីថ្ងៃនោះ មានន័យថាបន្ទាប់ពីគាត់ឈឺកផ្ដាសាយហើយ ក្រោយពីគាត់សម្រាក
គាត់សម្រាកពេញមួយថ្ងៃ ក្រោយពេលក្រោកដឹងខ្លួនគាត់ក៏ចាប់ផ្ដើមក្អក គាត់ក៏ចាប់ផ្ដើមក្អក
បន្ទាប់មកគាត់ក៏មានអារម្មណ៍ថាឈឺក្បាល ឈឺក្បាល កាន់តែខ្លាំងឡើងៗ
អញ្ចឹងអាការនៃជំងឺផ្ដាសាយក៏មានការឈឺក្បាលខ្លាំងផងដែរ
និងមានអារម្មណ៍ថាមុខរបស់យើងស្ពឹកដោយសារតែយើងផ្ដាសាយ តឹងច្រមុះ និងហៀរសំបោរ
និងហៀរសំបោរ និងក្អក និងក្អកផង ធ្វើឲ្យមុខរបស់យើងមានអារម្មណ៍ថាស្ពឹក
និងគាត់មានអារម្មណ៍ថាអស់កម្លាំងយ៉ាងខ្លាំង កាន់តែអស់កម្លាំង ដោយសារតែគាត់
ដោយសារតែគាត់ផ្ដាសាយធំ ដោយសារតែគាត់ផ្ដាសាយធំ និង ដោយសារតែគាត់ផ្ដាសាយធំ
និងក្ដៅខ្លួនខ្លាំង ដូច្នេះធ្វើឲ្យគាត់មានអារម្មណ៍ថាឈឺក្បាលខ្លាំង និង និងឈឺក្បាលខ្លាំង
និងអស់កម្លាំងខ្លាំងឡើងៗ។

បន្ទាប់មកទៀតរូបភាពទី ១៣ រូបភាពទី ១៣ គាត់ក៏បានថយមកគេងនៅលើសាឡុងរបស់គាត់
ដោយសារតែគាត់មានអាការកាន់តែ ដោយសារតែគាត់មានអាការ
ដោយសារតែគាត់មានអាការនៅក្នុងខ្លួនរបស់គាត់ មានអារម្មណ៍ថាកាន់តែមិនស្រួលខ្លួនខ្លាំង
ដោយសារតែក្ដៅខ្លួនផង ក្អកផង ឈឺកផង និងផ្ដាសាយ និងពិបាកដកដង្ហើមដោយសារតឹងច្រមុះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងធ្វើឲ្យគាត់មានអារម្មណ៍ថាអស់កម្លាំងយ៉ាងខ្លាំង អញ្ចឹងគាត់ក៏បានថយមក ថយមកគេងនៅលើសាឡុងរបស់គាត់ ដោយគាត់បានបើកទូរទស្សន៍ចោល អញ្ចឹងគាត់ គាត់បើក គាត់បានបើកទូរទស្សន៍ចោល និងគេងនៅលើសាឡុងរបស់គាត់ ដោយសារតែគាត់អស់កម្លាំងខ្លាំងពេក អស់កម្លាំងខ្លាំង និងដោយសារតែគាត់ញ៉ាំថ្នាំងងុយគេង ញ៉ាំថ្នាំផ្តាសាយផងដែរ អញ្ចឹងដោយសារតែថ្នាំផ្តាសាយ គឺមានជាតិងងុយគេង អញ្ចឹងនៅ និង ដោយសារតែ[ផ្តាសាយ] នៅពេលដែល ដោយសារតែនៅពេលដែលយើងឈឺគ្រុនផ្តាសាយ មានអារម្មណ៍ថាអស់កម្លាំង និងងងុយគេង និងត្រូវការគេងឲ្យបានច្រើន ដើម្បីឲ្យឆាប់ជា អញ្ចឹងយើងឃើញគាត់ក៏បានថយមកគេងនៅលើសាឡុងរបស់គាត់ម្តងទៀត។

បន្ទាប់មករូបភាពទី ១៤ រូបភាពទី ១៤ កន្លងទៅប្រហែលជា ៣ ថ្ងៃ គាត់ក៏មានអារម្មណ៍ថាធូរស្រាល គាត់ក៏មានអារម្មណ៍ថាធូរស្រាល និងមានអារម្មណ៍ថាស្រួលខ្លួនឡើងវិញ អញ្ចឹងយើងឃើញរូបភាពទី ១៤ គឺជារូបភាពបង្ហាញអំពីប្រតិទិន ដែលបង្ហាញអំពីថ្ងៃ អញ្ចឹងនៅក្នុងប្រតិទិនគឺបង្ហាញអំពី គឺបង្ហាញ ១២ ខែក្នុងមួយឆ្នាំ ដែលមានខែមករា ខែកុម្ភៈ ខែមីនា ខែមេសា ខែឧសភា ខែមិថុនា ខែកក្កដា ខែកក្កដា ខែសីហា ខែកញ្ញា ខែតុលា ខែវិច្ឆិកា និងខែធ្នូ។ និងនៅក្នុងមួយខែៗ ខែខ្លះគឺមាន គឺមាន ៣០ ថ្ងៃ ខែខ្លះមាន ៣១ ថ្ងៃ និងនៅខែខុស ខុស ខុសតែខែ ២ ខុសតែខែ ២ ពេលខ្លះមាន ២៨ ថ្ងៃ ខែ ២ គឺមាន ២៨ ថ្ងៃ និងខែខ្លះគឺមាន ២៩ ថ្ងៃ អញ្ចឹងនៅក្នុងប្រតិទិននៅក្នុងរូបភាពនេះ គឺថ្ងៃទី ១២ ១៣ និង ១៤ ក្រោយពេលកន្លងទៅរយៈពេល ៣ ថ្ងៃនេះ គឺធ្វើឲ្យគាត់មានអារម្មណ៍ថាស្រួលខ្លួនឡើងវិញ មានអារម្មណ៍ថាស្រួលខ្លួនឡើងវិញ។

បន្ទាប់មកទៀតរូបភាពទី ១៥ ក្រោយពេលដែលគាត់ស្រួលខ្លួនឡើងវិញ គាត់ក៏បានដើរចេញមកខាងក្រៅ គាត់ក៏បានដើរចេញមកខាងក្រៅ ដើម្បី ដើម្បីស្រូបយកខ្យល់អាកាស ដើម្បីស្រូបយកអាកាស ស្រូបយកខ្យល់អាកាស ដើម្បីឲ្យជំងឺផ្តាសាយរបស់គាត់ឆាប់ជា និងដើម្បីកុំឲ្យគាត់ស្រេ្តស មានន័យថានៅពេលដែលគាត់ឈឺផ្តាសាយ និងនៅតែក្នុងផ្ទះ នៅតែក្នុងផ្ទះពេលខ្លះគាត់មានអារម្មណ៍ថាស្រេ្តស និងធ្វើឲ្យគាត់កាន់តែឈឺ អញ្ចឹងនៅពេលដែលគាត់ស្រួលខ្លួនគាត់ក៏បានចេញមកខាងក្រៅ ដើម្បីស្រូបយកខ្យល់អាកាស ឬក៏នៅក្នុងរូបភាពទី ១៥ នេះគាត់ក៏បានចេញមកក្រៅ ដើម្បីដើរទៅធ្វើការ ដើម្បីដើរត្រលប់ទៅធ្វើការក្រោយពីគាត់ឈប់សម្រាករយៈពេល ៣ ថ្ងៃ ឈប់សម្រាករយៈពេល ៣ ថ្ងៃ ដោយគេងនៅផ្ទះ ដោយគេងនៅផ្ទះ នៅពេលដែលគាត់ នៅពេលដែលគាត់គ្រុន[ផ្តាសាយ] នៅពេលដែលគាត់ នៅពេលដែលគាត់គ្រុនផ្តាសាយខ្លាំង និងទទឹកភ្លៀង និងគាត់បាន[ចម្លង] គាត់បានឆ្លងជំងឺ គាត់បានឆ្លងជំងឺផ្តាសាយពីបុរសម្នាក់ដែលជិះឡានជាមួយគាត់ អញ្ចឹងធ្វើឲ្យគាត់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងធ្វើឲ្យគាត់អត់ស្រួលខ្លួន និងបានឈប់សម្រាកនៅផ្ទះរយៈពេល ៣ ថ្ងៃ រយៈពេលបីថ្ងៃ
ដោយមិនបានទៅធ្វើការ ដោយគាត់គ្រាន់តែ ដោយគាត់គឺគេងរហូតនៅក្នុងផ្ទះ និងញ៉ាំថ្នាំ
អញ្ចឹងរូបភាពទី ១៥ គាត់មានអារម្មណ៍ថាស្រួលខ្លួន បន្ទាប់មក
បន្ទាប់មកគាត់ក៏ចេញទៅខាងក្រៅស្រូប[...] ស្រូបយកខ្យល់អាកាសដើម្បីឲ្យ
ដើម្បីឲ្យគាត់មានអារម្មណ៍ថាស្រស់ស្រាយ ឬក៏គាត់ដើរចេញទៅ គាត់ដើរទៅធ្វើការនៅពេលព្រឹក
ក្រោយពេលគាត់ស្រួលខ្លួន និងក្រោយពេលគាត់ឈប់សម្រាករយៈពេល ៣ ថ្ងៃហើយ
អញ្ចឹងជំងឺផ្ដាសាយងាយស្រួលឆ្លង ដោយឆ្លងតាមវីរុស
ដែលឆ្លងតាមវីរុសនៅពេលដែលយើងឈរនៅជិតអ្នក នៅពេលដែលយើងឈរ
ឬក៏អង្គុយនៅក្បែរអ្នកដែលមានជំងឺផ្ដាសាយ អញ្ចឹងងាយស្រួលឆ្លងដោយយើងមិនបានពាក់ម៉ាស
ឬក៏ងាកមុខចេញ ប៉ុន្តែជំងឺផ្ដាសាយក៏ឆាប់ជាដែរដោយគ្រាន់តែយើងគេងសម្រាក និងញ៉ាំថ្នាំ
និងញ៉ាំទឹកក្ដៅៗ ញ៉ាំទឹកក្ដៅៗ និងគេងសម្រាកឲ្យបានច្រើនយើងនឹងឆាប់ជាពីជំងឺផ្ដាសាយនោះ
និងជាពិសេសការហាត់ប្រាណ ការហាត់ប្រាណក៏អាច ក៏ជួយយើងមួយផ្នែកឲ្យយើង
ក៏ជួយយើងមួយផ្នែក ក៏ជួយយើងមួយផ្នែក
មានន័យថាការហាត់ប្រាណធ្វើឲ្យប្រព័ន្ធនៅក្នុងខ្លួនរបស់យើងរឹងមាំ និងមិន[ងាយស្រួល] រឹងមាំនិង
និងមិនងាយស្រួលឆ្លងជំងឺផ្ដាសាយ បើទោះបីជាមានមេឃភ្លៀង
ឬក៏បើទោះបីជានៅជិតអ្នកដែលមានជំងឺផ្ដាសាយក៏ដោយ
នៅពេលដែលប្រព័ន្ធក្នុងខ្លួនរបស់យើងរឹងមាំ អញ្ចឹងយើងមានអារម្មណ៍ថា យើងមានអារម្មណ៍ថា គឺ
មិនឆាប់[ងាយស្រួល] មិនឆាប់ឆ្លងជំងឺផ្សេងៗពីអ្នកដទៃ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.